**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## និរាករណ៍អនុក្រឹត្យស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យស្តីពីការធ្វើអនុបយោគផ្ទៃដីក្នុងតំបន់ការពារធម្មជាតិ ក្នុងភូមិសាស្ត្រ ខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តសៀមរាប និងខេត្តកំពង់ស្ពឺ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១

ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-យោងសេចក្តីសម្រេចលេខ ១២៥សសរ ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១៤ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច

-យោងលិខិតលេខ ១៧៧១សជណ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

## សម្រេច

**មាត្រា ១**.-

១-ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យនានា សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន Investment and Development DAI NAM (Cambodia) J.S.C LTD លើផ្ទៃដីទំហំ **៨.៦៨៥ ហិកតា (ប្រាំបីពាន់ប្រាំមួយរយប៉ែតសិបប្រាំហិកតា)** ស្ថិតក្នុងដែនជម្រកសត្វព្រៃភ្នំព្រេច ស្រុកកែវសីមា ខេត្តមណ្ឌលគិរីដូចខាងក្រោម៖

- អនុក្រឹត្យលេខ **៩៨ អនក្រ.បក** ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព
- អនុក្រឹត្យលេខ **១៦៥ អនក្រ.បក** ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៨.៦៨៥ ហិកតា (ប្រាំបីពាន់ប្រាំមួយរយប៉ែតសិបប្រាំហិកតា)** ស្ថិតក្នុងដែនជម្រកសត្វព្រៃភ្នំព្រេច ស្រុកកែវសីមា ខេត្តមណ្ឌលគិរី។

២-ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យនានា សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន **ខូ វែលផ្លាស ខូអិលធីឌី** លើផ្ទៃដីទំហំ **៣.១១០ ហិកតា (បីពាន់មួយរយដប់ហិកតា)** ក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំព្រេច ភូមិសាស្ត្រខេត្តមណ្ឌលគិរី ដូចខាងក្រោម៖

-អនុក្រឹត្យលេខ **២១ អនក្រ.បក** ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-អនុក្រឹត្យលេខ **៤៧ អនក្រ.បក** ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៣.១១០ ហិកតា (បីពាន់មួយរយដប់ហិកតា)** ស្ថិតក្នុងដែនជម្រកសត្វព្រៃភ្នំព្រេច ក្នុងភូមិសាស្ត្រ ខេត្តមណ្ឌលគិរី។

**៣**-ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យនានា សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន **JING ZHONG TIAN CO.,LTD** លើផ្ទៃដីទំហំ **៩.៩៣៦ ហិកតា (ប្រាំបួនពាន់ប្រាំបួនរយសាមសិបប្រាំមួយហិកតា)** ក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ ភូមិសាស្ត្រស្រុកតាវែង ខេត្តរតនគិរីដូចខាងក្រោម៖

-អនុក្រឹត្យលេខ **៨៩ អនក្រ.បក** ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-អនុក្រឹត្យលេខ **២៤៤ អនក្រ.បក** ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៩.៩៣៦ ហិកតា (ប្រាំបួនពាន់ប្រាំបួនរយសាមសិបប្រាំមួយហិកតា)** ក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ ភូមិសាស្ត្រស្រុកតាវែង ខេត្តរតនគិរី ។

**៤**-ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យនានា សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន **FU SHENG HAI (Cambodia) CO.,LTD** លើផ្ទៃដីទំហំ **៧.០៧៩ ហិកតា (ប្រាំពីរពាន់ចិតសិបប្រាំបួនហិកតា)** ក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ ភូមិសាស្ត្រស្រុកតាវែង និងស្រុកអណ្តូងមាស ខេត្តរតនគិរី ដូចខាងក្រោម៖

-អនុក្រឹត្យលេខ **៨៣ អនក្រ.បក** ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-អនុក្រឹត្យលេខ **២៤៥ អនក្រ.បក** ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៧.០៧៩ ហិកតា (ប្រាំពីរពាន់ចិតសិបប្រាំបួនហិកតា)** ក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ ភូមិសាស្ត្រស្រុកតាវែង និងស្រុកអណ្តូងមាស ខេត្តរតនគិរី។

**៥**-ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យនានា សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន **ប៊ី.វី.ប៊ី (ខេមបូឌា) អេហ្គ្រីខលឈើរ ឌីវេឡុបមេន** (B.V.B (Cambodia) Agriculture Development Co., Ltd) លើផ្ទៃដីទំហំ **៣.១៣៤ ហិកតា (បីពាន់មួយរយសាមសិបបួនហិកតា)** ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ភូមិសាស្ត្រខេត្តសៀមរាប ដូចខាងក្រោម៖

-អនុក្រឹត្យលេខ **១៤ អនក្រ.បក** ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-អនុក្រឹត្យលេខ **៤៨ អនក្រ.បក** ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៣.១៣៤ ហិកតា (បីពាន់មួយរយសាមសិបបួនហិកតា)** ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ភូមិសាស្ត្រខេត្តសៀមរាប។

**៦**-ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យនានា សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន **យិះចៀ ផូវីហ្ស៊ីម ឌីវេឡុបមេន (ខេមបូឌា) ខមភេនី** លើផ្ទៃដីទំហំ **១.០០០ ហិកតា (មួយពាន់ហិកតា)** ក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដូចខាងក្រោម៖

- អនុក្រឹត្យលេខ **៧៧ អនក្រ.បក** ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព
- អនុក្រឹត្យលេខ **១៦៧ អនក្រ.បក** ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **១.០០០ ហិកតា (មួយពាន់ហិកតា)** ក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។

**មាត្រា ២**.-

ផ្ទៃដីដែលគ្របដណ្តប់ដោយបណ្តាអនុក្រឹត្យដែលត្រូវបាននិរាករណ៍ ដូចមានចែងក្នុង **មាត្រា ១** នៃអនុក្រឹត្យនេះ ត្រូវដាក់បញ្ចូលជាដីដែនជម្រកសត្វព្រៃភ្នំព្រេច ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ និងឧទ្យានជាតិវីរៈជ័យ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តពាក់ព័ន្ធ។

**មាត្រា ៣**.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤**.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តសៀមរាប និងខេត្តកំពង់ស្ពឺ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមករា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ